ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

# សេចក្តីប្រកាសព័ត៌មាន

*ថ្ងៃ អង្គារ ៩ រោច ខែ មិគសិរ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស.២៥៦៥*

*រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០២១*

## កិច្ចប្រជុំគណៈកម្មាធិការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងក្រុមការងារបច្ចេកទេស

## ស្តីពី

## ការត្រួតពិនិត្យតាមដានវឌ្ឍនភាព នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៣ ប្ញូក ២ ប្រចាំត្រីមាសទី ៣ ឆ្នាំ ២០២១

នាព្រឹកថ្ងៃ អង្គារ ៩ រោច ខែ មិគសិរ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០២១ វេលាម៉ោង ៩:០០នាទី, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានរៀបចំប្រជុំគណៈកម្មាធិការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងក្រុមការងារបច្ចេកទេស (Technical Working Group-TWG) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (គ.ហ.ស.) ដោយមានការចូលរួមពីសំណាក់ឯកឧត្តម លោកជំទាវ ជាថ្នាក់ដឹកនាំ និងសមាជិកក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួង-ស្ថាប័ន, តំណាងដៃគូអភិវឌ្ឍន៍, មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត និងអង្គការមិនមែនរដ្ឋាភិបាល ។

តាមរបាយការណ៍វឌ្ឍនភាពកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៣ ប្លុក ២ ប្រចាំត្រីមាសទី ៣ ឆ្នាំ ២០២១, ការអនុវត្តការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈជារួម មានវឌ្ឍនភាពល្អប្រសើរ ទោះបីជាស្ថិតក្នុងស្ថានភាពមានវិបត្តិកូវីដ ១៩ ក៏ដោយ ។ ជាក់ស្តែង, ការប្រមូលចំណូលសរុប ក្នុងរយៈពេល ៩ ខែ បានប្រមាណ ១៥ ៨៩៥ ប៊ីលានរៀល ស្មើនឹង ៧៥% ធៀបនឹងច្បាប់ ដែលវឌ្ឍនភាពនៃការប្រមូលចំណូលនេះជាកំណើនដែលងើបឡើងវិញ និងល្អប្រសើរបើធៀបនឹងការអនុវត្តនៅក្នុងរយៈពេលដូចគ្នានៅឆ្នាំ ២០២០ ។ ការអនុវត្តចំណាយ, រាជរដ្ឋាភិបាលបានផ្តោតការយកចិត្តទុកដាក់ជាចម្បងលើវិស័យសង្គមកិច្ច ដែលការចំណាយលើវិស័យនេះអនុវត្តបានប្រមាណ ៩៨% ធៀបនឹងច្បាប់ បើគិតត្រឹមខែវិច្ឆិកា ឆ្នាំ ២០២១ និងរំពឹងថាការអនុវត្តចំណាយរដ្ឋសរុបប្រចាំឆ្នាំអាចនឹងសម្រេចបានក្នុងកម្រិតប៉ាន់ស្មាន ១០៨.៧% ធៀបនឹងច្បាប់ ។ ការណ៍នេះ អាចឆ្លុះបញ្ចាំងយ៉ាងច្បាស់អំពីប្រសិទ្ធភាពនៃការពង្រឹងភាពជឿទុកចិត្តនៃថវិកា នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលផ្តល់ឱ្យរាជរដ្ឋាភិបាលកម្ពុជានូវភាពគ្រប់គ្រាន់នៃសាច់ប្រាក់នៅក្នុងពេលមានវិបត្តិ ដើម្បីដោះស្រាយបញ្ហាបន្ទាន់ចំពោះមុខ ក៏ដូចជាការបន្តនិរន្តរភាពការងារប្រចាំថ្ងៃបានរលូន ។

ជាមួយគ្នានេះ, **ដៃគូអភិវឌ្ឍន៍** ក៏បានអបអរសាទរដល់សមិទ្ធផលដែលសម្រេចបាន និងបង្ហាញពីឆន្ទៈចូលរួម និងការត្រៀមខ្លួនរួចជាស្រេចក្នុងការបន្តគាំទ្រដល់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីសម្រេចបាន

នូវកំណែទម្រង់ប្រកបដោយចីរភាព ។ **ដៃគូអភិវឌ្ឍន៍** បានបង្ហាញគោលជំហរចូលរួមគាំទ្រកម្ពុជា ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើនប្រាក់ចំណូលក្នុងស្រុកក្នុងការគាំទ្រដល់ការស្តារឡើងវិញក្រោយវិបត្តិជំងឺកូវីដ-១៩, ចូលរួមក្នុងការបង្កើនចំណាយសង្គម, ចូលរួមគាំទ្រការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈបៃតង (Green PFM) ដើម្បីគាំទ្រគោលនយោបាយអាកាសធាតុវេទយិតភាព (Climate-Sensitive Policies) និងការគាំទ្របច្ចេកទេសរៀបចំសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ និងភាគកម្មសាធារណៈជាដើម ។ **ដៃគូអភិវឌ្ឍន៍** ក៏បានផ្តល់ជាមតិយោបល់សំខាន់ៗបន្ថែមជុំវិញការពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេស ស្នើសុំការស្វែងយល់ពី ផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការស្តារសេដ្ឋកិច្ចប្រទេសឡើងវិញក្រោយវិបត្តិកូវីដ-១៩ ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានលើកឡើងពីយុទ្ធសាស្ត្រចំនួន ២ របស់រាជរដ្ឋាភិបាល ក្នុងការឈានទៅរកការបើកប្រទេសឡើងវិញក្រោយវិបត្តិកូវីដ-១៩ គឺ÷

**ទី១.** យុទ្ធសាស្ត្រស្តីពីការរស់នៅតាមគន្លងប្រក្រតីថ្មីក្នុងបរិបទនៃជំងឺកូវីដ-១៩ និង

**ទី២.** ក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចក្នុងការរស់នៅជាមួយជំងឺកូវីដ-១៩ តាមគន្លងប្រក្រតីថ្មី ឆ្នាំ ២០២១-២០២៣ តាមរយៈការផ្តល់អាទិភាពទៅលើចំណុចចំនួន ៣ ដែលរួមមាន÷

១. ការស្តារឡើងវិញនូវវិស័យដែលរងការប៉ះពាល់ខ្លាំង,

២. ការកែទម្រង់សំខាន់ៗជារចនាសម្ព័ន្ធ និង

៣. ការកសាងភាពធន់ដើម្បីត្រៀមខ្លួន និងការឆ្លើយតបទៅនឹងជំងឺ ឬស្ថានភាពស្រដៀងគ្នាដែលអាចផ្ទុះឡើងនាពេលអនាគត ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក៏បានគូសបញ្ជាក់ពីសារៈសំខាន់នៃការគៀគររកធនធានបន្ថែមតាមរយៈ÷

១. ការបន្តកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍នានា ដោយស្នើឱ្យដៃគូអភិវឌ្ឍន៍ពិនិត្យមើលលទ្ធភាពជាក់ស្តែងក្នុងការជួយគាំទ្រទាំងផ្នែកធនធាន និងហិរញ្ញប្បទាន និង

២. លទ្ធភាពរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការគៀគរចំណូល តាមរយៈយន្តការបោះផ្សាយមូលបត្ររដ្ឋ, ការពង្រឹងភាពជាដៃគូរវាងរដ្ឋនិងវិស័យឯកជនសម្រាប់រយៈពេលមធ្យម និងវែង និង កិច្ចសហប្រតិបត្តិការគ្នារវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា ក្នុងការអនុវត្តគោលនយោបាយរូបិយវត្ថុក្នុងការជំរុញឱ្យមានការចូលរួមពីវិស័យធនាគារដើម្បីធានាបាននូវសន្ទនីយភាព (liquidity) ដោយផ្អែកលើអភិក្រមប្រុងប្រយ័ត្នខ្ពស់លើការផ្តល់ហិរញ្ញប្បទានដល់សកម្មភាពអាជីវកម្ម និងកិច្ចការធុរកិច្ចក្នុងវិស័យអាទិភាព ដើម្បីធាននូវស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និងរូបិយបណ្ណជាតិ ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក៏បានថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងកន្លងមក របស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគ្រប់អង្គភាពនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រហូតសម្រេចបានសមិទ្ធផលនៅត្រីមាសទី ៣ នេះ និងបានស្នើគ្រប់អង្គភាពពាក់ព័ន្ធ បន្តជំរុញការអនុវត្តផែនការសកម្មភាពរួមដំណាក់កាលទី ៣ បូក ២ ដើម្បីសម្រេចតាមគោលដៅដែលបានគ្រោងទុក ៕